# បទអប់រំខ្លី

## ស្តីអំពី: "សេចក្តពិតនៃជីវិត"



*ជីវិតនេះ ជាអរូបធម៌ ឬនាមធម៌អាចសម្គាល់បានដោយចលនា (ការកម្រើកញាប់ញ័រ) នៃឥរិយាបថទាំង៤ គឺ ដេក ដើរ ឈរ អង្គុយ ឬដោយកាយវិការណាមួយ មានកម្រើក ឬហាមាត់និយាយស្តីបាន ឬក៏នៅមានខ្យល់ដកដង្ហើមចេញចូលគ្រប់វិនាទី ។*

*ជីវិតនេះ ជារបស់ផ្សំដោយវត្ថុធាតុ ឬធម្មជាតិច្រើនយ៉ាងមានបឋវីធាតុ(ធាតុដី) ជាដើម ក្រោយអំពីធាតុផ្សំទាំងអស់ បានជួបជុំនៅក្នុងជម្រក ឬកន្លែងរួមគ្នាហើយ ក៏បង្កើតបានជា*

ចលនាមួយ ដែលយើងសន្មតហៅថា"**ជីវិត**"ប្រែថា ការរស់នៅ ឬធម្មជាតិជាគ្រឿងប្រព្រឹត្តទៅនៃសត្វ ឬថាធម្មជាតិរស់នៅនៃសត្វ ឬក៏ថាធម្មជាតិជាទីប្រព្រឹត្តទៅនៃសម្បយុត្តធម៌ ។

ជីវិតនេះ មានសេចក្តីទុក្ខលំបាកណាស់ បានជាសត្វលោកគ្រប់គ្នា ត្រូវទុក្ខលំបាកគ្រប់សព្វគ្រប់ ព្រោះដោយអវិជ្ជាបិទបាំងមិនស្គាល់ការពិតនៃសេចក្តីទុក្ខ ។ នៅក្នុង**ធម្មបទដ្ឋកថាភាគ៣ ក្នុងទំព័រ៣១** ព្រះសម្មាសម្ពុទ្ធព្រះអង្គបានសម្តែងអំពីសេចក្តីទុក្ខនេះថា៖



**អនិមិត្តមនញ្ញាតំ មច្ចានំ ឥធ ជីវិតំ**
**កសិរញ្ច បរិត្តញ្ច តញ្ច ទុក្ខេន សំយុតំ។**

*ជីវិតរបស់សត្វទាំងឡាយ ក្នុងលោកនេះ បុគ្គលណាមួយមិនអាចកំណត់បាន មិនអាចដឹងបានទេ ជាធម្មជាតលំបាកផង មានប្រមាណតិចតួចផង ព្រោះជីវិតនោះ តែងត្រូវសេចក្តីទុក្ខគ្របសង្កត់ ។*

**សេចក្តីអធិប្បាយ**

**១.អនិមិត្តំ** *ជីវិតសព្វសត្វទាំងឡាយក្នុងលោកនេះ ពុំមានបុគ្គលណាមួយកំណត់បានទេ ក្នុងការកើតនិងស្លាប់ ។ ដែលថាកំណត់មិនបាន នោះ តើជីវិតនេះមកពីណា មកចាប់បដិសន្ធិក្នុង*



*ផ្ទៃនៃមាតា? កាលបើប្រសូតមកហើយ តើស្ថិតនៅប៉ុន្មានថ្ងៃ? ប៉ុន្មានខែ? ប៉ុន្មានឆ្នាំ? ដែលធ្លាប់និយាយថា បានអាយុប៉ុន្មាន? លុះដល់វេលាជីវិត*

នេះរលត់បែកធ្លាយទៅវិញ តើជីវិតហ្នឹងទៅកើត នៅកន្លែងណាទៀត ក្នុងត្រកូលណា? ភូមិណា? ស្រុកណា? ភពណា? មានពូជពង្សវង្សត្រកូលជាអ្វី? ពុំមានបុគ្គលណាកំណត់បានទេ ឬថាជីវិតនេះ មិនមានបុគ្គលណាកាត់តម្លៃថាប៉ុណ្ណេះ ឬថាប៉ុណ្ណោះបាន ដូចជាទំនិញក្នុងផ្សារឡើយ ។

**២.អនញ្ញាតំ** ជីវិតនេះ មិនមានអ្នកណាម្នាក់អាចដឹងបានថា ជីវិតនេះ មានការប្រព្រឹត្តទៅយ៉ាងណាៗទេ ក្នុងអនាគតកាល ក្នុងថ្ងៃនេះ យើងដឹងថា ជីវិតមានការប្រព្រឹត្តយ៉ាងនេះ យ៉ាងនោះរួចហើយ ប៉ុន្តែថ្ងៃស្អែកទៀត ពុំដឹងជីវិតនេះ



មានការប្រព្រឹត្តផ្លាស់ប្តូរដូចម្តេចទេ ។ សូម្បីតែម្ចាស់ជីវិតហ្នឹង មិនដឹងថា ជីវិតត្រូវបែកធ្លាយក្នុង

ពេលណាដែរ ទាំងចលនាការប្រព្រឹត្តទៅធម្មតា របស់ជីវិត តាមធម្មជាតិនោះ ក៏យើងពុំបានដឹង ទាំងអស់ ។

**៣.កសិរញ្ញ**ជីវិតនេះ មានសេចក្តីលំបាក នឹងបីបាច់ថែរក្សាណាស់ ព្រោះជីវិតរបស់មនុស្ស ម្នាក់ៗ ដែលអាចឋិតថេរចីរកាលបានទាល់តែ



ម្ចាស់ជីវិតគ្រប់រូប បេះផ្គត់ផ្គង់ថែរក្សា រកគ្រឿង សម្ភារៈបរិក្ខារប្រដាប់ប្រដាសម្រាប់ ឲ្យជីវិតរស់ នៅបានគ្រប់គ្រាន់បរិបូណ៌ ទើបជីវិតរស់នៅ បាន ។ វត្ថុធម្មជាតិទាំងអស់ ដែលជីវិតប្រាស្រ័យ ទាក់ទងនោះ សុទ្ធតែជារបស់ពិបាករក ពិបាក សន្សំ ពិបាកប្រមូល សម្រាប់យកមកចិញ្ចឹមជីវិត

ហើយវត្ថុទាំងអស់នេះទៀត ត្រូវប្រើមធ្យោបាយល្អិតល្អន់ណាស់ ក្នុងការរកក្នុងការរក្សា ។ ជីវិតនេះមានការលំបាកពុំចេះចប់សោះ ការលំបាកនេះពុំមែនតែអ្នកទ័លក្រកម្សត់ទុគ៌តទេ សូម្បីពួកជនដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានយសស័ក្តិឬឫទ្ធិអំណាច ក៏នៅតែមានការទុក្ខលំបាកធ្លាក់មកលើជីវិតគ្រប់រូបទាំងអស់ បើមិនច្រើន ក៏តិចដែរ មិនអាចមានជីវិតណាមួយ គេចវេះចៀសវាងផុតបានទេ ។

**៤.បរិត្តញ្ញា** ជីវិតរបស់មនុស្សសត្វ មានប្រមាណតិចតួចស្តួចស្តើងណាស់ ខ្លីណាស់ តិចណាស់ ឆាប់រេចរឹល ឆាប់សឹក ឆាប់របេះរបោចរង្គេះរង្គើ ផុះធ្លាយពុកផុយណាស់ មិនជាប់មាំពូកែទេ ។ សូម្បីម្ចាស់ជីវិត មានមធ្យោបាយគ្រប់គ្រាន់សម្រាប់ធ្វើជីវិតឲ្យរស់នៅ ក៏ជីវិតនេះ មិនព្រមរស់នៅក៏មានដែរ ។ បុគ្គលដែលស្ងាប់

បាត់បង់ជីវិត ពុំមែនសុទ្ធតែស្លាប់ដោយសារអត់បាយទឹក ម្ហូបចំណីអាហារប្រដាប់ប្រដាប្រើប្រាស់



ប៉ុណ្ណោះទេ មនុស្សខ្លះស្លាប់នៅកណ្ដាលទ្រព្យសម្បត្តិប្រដាប់ប្រដា ប្រើប្រាស់សម្លៀកបំពាក់ម្ហូបអាហារ ទីសេនាសនៈ ឱសថ ភេសជ្ជៈគ្រប់បរិបូណ៌ ប៉ុន្តែពេលវេលា ថ្ងៃ ខែ ឆ្នាំ ដែលកន្លងទៅទទេៗ សុទ្ធតែស្រូបយកជីវិត ទៅជាមួយគ្រប់វិនាទីទាំងអស់ ។

**៥.តញ្ហា ទុក្ខេន សំយុត្តំ** ជីវិតនេះ ត្រូវសេចក្ដីទុក្ខ គ្របសង្កត់ជិះជាន់ចោមរោមឡោមព័ទ្ធរៀងរាល់ពេល ឥតមានទំនេរស្រាកស្រាន្តសោះឡើយ ។ ដរាបណា មនុស្សនៅ មានអវិជ្ជា

និងតណ្ហា បិទបាំង សេចក្តីទុក្ខគ្រប់យ៉ាងរបស់ជីវិតក៏នៅមានដរាបនោះ សេចក្តីទុក្ខទាំងអស់ក្នុងបច្ចុប្បន្ននេះ ជាទុក្ខល្មាក់ល្មមមិនទាន់ចាត់ថា ជាសេចក្តីទុក្ខធំនៅឡើយទេ សេចក្តីទុក្ខដែលធំនោះគឺនៅគ្រប់កំណើតរបស់សត្វ ។

ជីវិតតែងជួបនូវទុក្ខមិនចេះចប់ បើមិនទាន់បានសម្រេចនូវអមតនិព្វានទេ ជីវិតសត្វលោកក៏នៅអវិជ្ជានេះ ខាំមិនឲ្យឃើញអ្វីឡើយក្រៅពីទុក្ខលំបាកនោះ អ៊ុចឹងហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់ឲ្យរក្សាចិត្តឲ្យបានល្អ មិនឲ្យអវិជ្ជាគ្របសង្កត់បាន ហើយត្រូវរក្សាចិត្តហ្នឹងឲ្យ



បានល្អ មិនឲ្យត្រាច់ទៅកាន់ទីដទៃ នាំឲ្យអវិជ្ជាបិទបាំង បើយើងរក្សាចិត្តបានល្អទើបសេចក្តីទុក្ខមិនសូវកើតឡើង ដូចព្រះបរមសាស្តាទ្រង់សម្តែងថា "**ចិត្តំ គុត្តំ សុខាវហំ**" ការទូន្មានចិត្តបាន រមែងនាំមកនូវសេចក្តីសុខ ឬថាការគ្រប់គ្រងចិត្តបាន រមែងនាំមកនូវសេចក្តីសុខ ៕

ប្រែសម្រួលពីធម្មបទដ្ឋកថាបាលី ភាគ៣ ទំព័រ៣១

ដោយ សាមណេរសុវណ្ណប្បញ្ញោ
**ស្វាត់ សុឆើត**
ឧទ្ទេសាចារ្យ **លី ប៊ុនលីន**
កែសម្រួល សំណេរនេះដោយ
**លោកគ្រូព្រះមហាធម្មវលញ្ចារោ ចាន់ សុជន**

ប្រធាន កម្មវិធីមនុស្សជម៌វត្តប្រាសាទស្រះ

កណ្តាល(ខ្ទាស់)

**ថ្នានពិនិត្យ និងឯកភាព**

*ធ្វើនៅវត្តប្រាសាទស្រះកណ្តាល(ខ្ពស់) ថ្ងៃ៨កើត ខែទុតិយាសាឍ ព.ស.២៥៥៩ ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី២៣ ខែកក្កដា ឆ្នាំ២០១៥ ។*